# ជំពូក៨ – ស្រី សុធារី

## ផ្សព្វផ្សាយសន្តិភាពតាមរយៈកិច្ចសន្ទនាអន្តរសាសនាក្នុងសហគមន៍



រូបថត៖ សុធារីនៅការិយាល័យអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ នៅក្រុងភ្នំពេញ ឆ្នាំ២០២៤។ ថតដោយ ឃ្លាំង ប៉ូលីន័រ អង្គការទោរវើម៉ូត្រិភាព។

ការធ្វើដំណើរដ៏លំបាករបស់កម្ពុជាទៅរកសន្តិភាព ដែលមិនទាន់មានស្ថិរភាព និងលទ្ធិប្រជាធិបតេយ្យ ដែលទើបនឹងចាប់ផ្តើម វាបានជំរុញឱ្យមានជំនាន់ថ្មីនៃអ្នកកសាងសន្តិភាព ដែលប្តេជ្ញាចិត្តព្យាបាលសង្គមរបស់ខ្លួន។ ក្នុងចំណោមអ្នកទាំងនោះ **ស្រី សុធារី** នាយិកាប្រតិបត្តិនៃអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT) មានឈ្មោះល្បីថា ជាស្ត្រីម្នាក់ដឹកនាំការខិតខំប្រឹងប្រែងសម្រាប់សន្តិភាព។ គាត់ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាតួអង្គសំខាន់ម្នាក់ក្នុងចលនាកសាងសន្តិភាព ដឹកនាំដោយកម្ពុជា ដែលបានចូលរួមបម្លែងជម្លោះរយៈពេលវែង ការព្យាបាលសង្គម និងការផ្សះផ្សានៅក្នុងសម័យក្រោយសង្គ្រាម។

នៅក្នុងប្រទេសមួយដែលសំឡេងស្ត្រីជាញឹកញាប់ត្រូវបានមើលរំលងក្នុងដំណើរការសន្តិភាព សុធារី គឺជាស្ត្រីដែលមានភាពលេចធ្លោនៅចុងឆ្នាំ២០០០ ដែលជាអ្នកតស៊ូមតិដ៏ខ្លាំងក្លាសម្រាប់កិច្ចសន្ទនាអន្តរសាសនា ការផ្សះផ្សាសហគមន៍ និងការចូលរួមរបស់ស្ត្រីនិងយុវជនក្នុងការកសាងសន្តិភាពប្រកបដោយចីរភាព។ រឿងរ៉ាវរបស់គាត់ ដែលមានមូលដ្ឋានលើធាតុផ្សំទាំងបួននៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គឺការចូលរួម ការបង្ការនិងទប់ស្កាត់ ការការពារ និងការសង្គ្រោះនិងស្តារឡើងវិញ បង្ហាញពីរបៀបដែលការអត់ធ្មត់ ភាពសុភាពរាបសា និងភាពដឹកនាំនៅមូលដ្ឋានអាចបម្លែងសហគមន៍ក្រោយជម្លោះបាន។

## ដំណើរដំបូងក្នុងការកសាងសន្តិភាព

សុធារីបានចាប់កំណើតបន្ទាប់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម (១៩៧៥–១៩៧៩) បានបញ្ចប់។ គាត់បានធំធាត់ឡើងក្នុងសង្គមមួយ ដែលកំពុងស្តារឡើងវិញពីការបំផ្លាញដោយសង្គ្រាម។ ការជំរុញទឹកចិត្តដំបូងរបស់គាត់បានមកពីម្តាយដែលជាអ្នករស់រានមានជីវិតពីការប្រល័យពូជសាសន៍ និងបានចូលរួមក្នុងក្រុមស្ម័គ្រចិត្តគ្រីស្ទាននៅកម្ពុជា។ ម្តាយបានណែនាំគាត់ឱ្យចូលរួមការងារស្ម័គ្រចិត្តតាំងពីនៅក្មេង។ សុធារីបានធ្វើជាអ្នកបកប្រែក្នុងសកម្មភាពសហគមន៍របស់ម្តាយគាត់ ជាបទពិសោធដែលគាត់និយាយថាបានបង្កើតមូលដ្ឋានសម្រាប់ជំនឿគ្រីស្ទាន និងការទទួលខុសត្រូវចំពោះអ្នកដទៃ។

បទពិសោធដំបូងទាំងនេះ បានបង្កើតជំនឿរបស់គាត់ថា ជំនឿនិងកិច្ចសន្ទនាអាចជាឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់សន្តិភាព ហើយបានដាក់គាត់លើផ្លូវទៅរកវិជ្ជាជីវៈកសាងសន្តិភាព។ ជាអ្នកជំនាញវ័យក្មេង គាត់បានចូលរួមជាអ្នកគ្រប់គ្រងគម្រោងសាសនាផ្សេងៗ និងអ្នកស្រាវជ្រាវនៅ ACT ក្នុងឆ្នាំ២០០៩ ហើយបន្តឡើងកាន់តំណែងជានាយិកាប្រតិបត្តិ។ ក្រៅពីបម្រើការងារនៅ ACT គាត់ក៏បានធ្វើការងារស្ម័គ្រចិត្តជាមួយក្រុមការងារសម្រាប់សន្តិភាព (WGP) ដែលជាបណ្តាញស្ម័គ្រចិត្តសម្រាប់ការបង្ការជម្លោះ។ ក្នុងពេលនោះគាត់ក៏បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងវិស័យរដ្ឋបាលអាជីវកម្ម (MBA) ក្នុងឆ្នាំ២០១០ និងបន្តសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ក្នុងវិស័យសន្តិភាព និងជម្លោះ ហើយក៏បានចូលរួមវគ្គសិក្សាខ្លីៗពីសន្តិភាពនៅប្រទេសហ្វីលីពីន និងប្រទេសថៃ ដើម្បីបង្កើនជំនាញបន្ថែម។

ព្រឹត្តិការណ៍សំខាន់មួយក្នុងឆ្នាំ២០០៩ នៃការតានតឹងនៅព្រំដែនកម្ពុជា–ថៃជិតប្រាសាទព្រះវិហារបានបង្កជាជម្លោះប្រដាប់អាវុធ។ សុធារីដែលជាយុវតីវ័យក្មេងបានចូលរួមជាមួយគណៈប្រតិភូសន្តិភាពសាសនានិងជនជាតិផ្សេងៗ ដើម្បីជួយបន្ថយភាពតានតឹងនេះ។

*«យើងបានបង្កើតកម្មវិធីប្តូរបទពិសោធរវាងយុវជនថៃ–ខ្មែរ និងកិច្ចសន្ទនារវាងសហគមន៍ជនជាតិនៅតាមព្រំដែន ដើម្បីបង្កើនការយល់ដឹង និងសុខុមាលភាពក្នុងចំណោមប្រជាជន។ ដូច្នេះនៅពេលមានភាពតានតឹង យើងបានទៅព្រំដែន និងព្យាយាមកសាងសន្តិភាពតាមរយៈទស្សនៈសាសនា»។*

ក្នុងអំឡុងពេលមានការបាញ់ផ្លោងដាក់គ្នា *«យើងអាចឮសំឡេងគ្រាប់បែក និងការបាញ់ប្រហារ ដូច្នេះវាមិនមានសុវត្ថិភាពទេ។ យើងអាចមានអារម្មណ៍ដីរង្គើនៅពេលមានការផ្ទុះម្តងៗ»។* គាត់បានរំលឹកពីក្រុមរបស់គាត់ដែលបានដឹកនាំការធ្វើអធិស្ឋានអន្តរសាសនានៅព្រំដែន ដោយនាំព្រះសង្ឃ និងមេដឹកនាំសាសនាផ្សេងៗទៀតទាំងសងខាងមកអធិស្ឋានដើម្បីសន្តិភាព។ ទោះបីជាមានគ្រោះថ្នាក់ក៏ដោយ សុធារីបានពិពណ៌នាថា ក្រុមសន្តិភាពបានភ្ជាប់ទំនាក់ទំនងជាមួយភាគីទាំងអស់ ដើម្បីគ្រប់គ្រងហានិភ័យ និងរៀបចំយុទ្ធសាស្ត្រយ៉ាងមានប្រសិទ្ធភាព៖

*«យើងបានរក្សាទំនាក់ទំនងជាមួយយោធា និងអាជ្ញាធរមូលដ្ឋានទាំងសងខាង។ ពួកគេមិនបានគាំទ្រយើងទេ ប៉ុន្តែពួកគេយល់អំពីអ្វីដែលយើងកំពុងព្យាយាមធ្វើ»។*

សកម្មភាពប្រកបដោយភាពច្នៃប្រឌិតនេះ មានគោលបំណងផ្តល់កន្លែងសម្រាប់សន្ទនាក្នុងស្ថានភាពតានតឹង ដើម្បីបន្ថយការភ័យខ្លាច និងរំលឹកឱ្យមនុស្សគ្រប់គ្នាចងចាំពីមនុស្សធម៌រួមគ្នា។ សម្រាប់សុធារី តួនាទីសាសនាមានសារៈសំខាន់ណាស់។ នៅពេលសួរថា តើការសន្ទនាសាសនាអាចជាជម្រើសមិនបង្កជម្លោះដែលជាប់ទាក់ទងនឹងភាគីជម្លោះបានដែរឬទេ? គាត់បានឆ្លើយថា៖ *«សាសនាជាវិធីសាស្ត្រមួយនៃការយល់ដឹងអំពីខ្លួនឯង ដែលជួយឱ្យមនុស្សសម្រាក និងពិចារណាអំពីអ្វីដែលត្រឹមត្រូវ។ សាសនាអាចគ្រប់គ្រងអារម្មណ៍មនុស្ស និងធ្វើឱ្យគេគិតអំពីអ្វីដែលគួរធ្វើ»*។ គាត់ក៏បានបញ្ជាក់ពីភាពមិនត្រឹមត្រូវនៃសង្គ្រាម នៅពេលដែលបង្ហាញតាមទស្សនៈសាសនា៖ *«យើងគួរប្រាប់ឱ្យពួកគេឈប់ឈ្លោះគ្នា ហេតុអ្វីបានជាថៃនិងខ្មែរប្រយុទ្ធគ្នា បើអ្នកទាំងពីរសុទ្ធតែជាពុទ្ធសាសនិកដូចគ្នា? ហើយហេតុអ្វីបានជាគ្រីស្ទាន និងមូស្លីមប្រយុទ្ធគ្នា បើអ្នកទាំងពីរដើរតាមព្រះតែមួយ?»*

បទពិសោធនៅព្រំដែនព្រះវិហារបានបង្រៀនសុធារីថា ការបង្ការជម្លោះចាប់ផ្តើមពីមូលដ្ឋានជាមួយនឹងការយល់ដឹងពីវប្បធម៌និងភាពរួបរួមគ្នា។ វាបានបង្កើតជំនឿរបស់គាត់ថា ជំនឿអាចជាឧបករណ៍តភ្ជាប់ដ៏មានឥទ្ធិពលក្នុងពេលមានវិបត្តិ។

បន្ទាប់ពីព្រឹត្តិការណ៍នៅព្រំដែន សុធារីបានបន្តចូលរួមយ៉ាងជ្រៅក្នុងសកម្មភាពសង្គមស៊ីវិលសម្រាប់សន្តិភាព។ តាមរយៈ WGP គាត់បានចូលរួមជាមួយក្រុមយុវជនកម្ពុជា ដែលមានចំណង់ចំណូលចិត្តចរចាជម្លោះ និងអប់រំសន្តិភាព។ ការងារនៅមូលដ្ឋាននោះ ជាមួយនឹងតួនាទីកាន់តែធំនៅ ACT បានផ្តល់មូលដ្ឋានរឹងមាំសម្រាប់ការចរចា និងការចូលរួមសហគមន៍។ ទោះបីជាតួនាទីរបស់គាត់កើនឡើងក៏ដោយ តែគាត់នៅតែចូលរួមស្តាប់មនុស្សចាស់និងយុវជននៅតាមភូមិ ដើម្បីយល់ពីទស្សនៈនៅមូលដ្ឋាន៖ *«យើងត្រូវទៅរកអ្នកភូមិ យើងត្រូវយល់ពីបញ្ហារបស់ពួកគេនៅក្នុងភូមិពួកគេ»*។ គាត់បានបញ្ជាក់ ដើម្បីបង្ហាញពីទស្សនៈនៃការចូលរួមដែលជាមូលដ្ឋាននៃការងាររបស់គាត់។

## កិច្ចសន្ទនាអន្តរសាសនា និងការផ្សះផ្សាសហគមន៍

ការរួមចំណែកដ៏សំខាន់មួយរបស់សុធារី គឺភាពជាអ្នកដឹកនាំក្នុងការប្រើប្រាស់កិច្ចសន្ទនាអន្តរសាសនា ជាវិធីសាស្ត្រសម្រាប់កសាងសន្តិភាព។ ACT គឺជាអង្គការដែលគាត់ដឹកនាំក្នុងពេលបច្ចុប្បន្ន ដែលបានលើកស្ទួយកិច្ចសហការរវាងជនជាតិ និងសាសនាផ្សេងៗជាយូរមកហើយ ដែលសុធារីក៏បានឈានមុខនៃការខិតខំប្រឹងប្រែងទាំងនេះតាំងពីដើមរៀងមក។

នៅដំណើរដំបូង គាត់បានគ្រប់គ្រងគម្រោងសន្តិភាពអន្តរសាសនារបស់ ACT ដែលបានបង្កើតបណ្តាញមូលដ្ឋានរបស់ព្រះសង្ឃពុទ្ធសាសនា អ៊ីម៉ាំអ៊ីស្លាម អ្នកបង្រៀនគ្រីស្ទាន និងមន្ត្រីធម្មការ ដើម្បីសម្រុះសម្រួលជម្លោះក្នុងសហគមន៍។ វិធីសាស្ត្រនេះសាមញ្ញ ប៉ុន្តែមានប្រសិទ្ធិភាព៖ អ្នកដឹកនាំតំណាងសាសនាផ្សេងៗមកជួបជុំគ្នា ដើម្បីដោះស្រាយបញ្ហាសហគមន៍ និងបង្ហាញពីសាមគ្គីភាព។

បណ្តាញទាំងនេះបានជំរុញកិច្ចសន្ទនានៅភូមិដែលមានហានិភ័យជម្លោះ បង្កើតសកម្មភាពរួម ដូចជាការដាំដើមឈើនៅតំបន់ដែលព្រៃឈើត្រូវបានបំផ្លាញ និងអបអរសាទរព្រឹត្តិការណ៍សំខាន់ៗ។ ឧទាហរណ៍ក្នុងឆ្នាំ២០១៨ ACT បានអបអរសាទរបុណ្យសប្តាហ៍សាមគ្គីអន្តរសាសនាពិភពលោករបស់អង្គការសហប្រជាជាតិ (UN) ដោយរៀបចំសកម្មភាពអន្តរសាសនានៅខេត្តឧត្តរមានជ័យក្រោមប្រធានបទ៖ «ការពារព្រៃ ការពារជីវិត» ដោយបញ្ចូលការសហការផ្នែកសាសនាជាមួយសន្តិភាពបរិស្ថាន។ សកម្មភាពនេះ បង្ហាញពីរបៀបដែលសុធារី និងអង្គការរបស់គាត់បានប្រើប្រាស់វេទិកាសាសនា ដើម្បីលើកស្ទួយសាមគ្គីភាព និងការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព។[1] កិច្ចប្រឹងប្រែងបែបនេះ ក៏បានកសាងទំនុកចិត្តរវាងជនជាតិ និងសាសនាផ្សេងគ្នា ដែលជាជំហានមួយដ៏សំខាន់ ដើម្បីពង្រឹងសង្គមបន្ទាប់ពីជម្លោះ។

ឧទាហរណ៍ដ៏ច្បាស់លាស់មួយទៀតអំពីការងារកសាងសន្តិភាពរបស់សុធារី គឺនៅតំបន់ព្រំដែនភាគឦសាននៃប្រទេសកម្ពុជា។ នៅខេត្តមណ្ឌលគិរីឆ្ងាយដាច់ស្រយាល គាត់បានដាក់ខ្លួនក្នុងការងារជាមួយស្ត្រី និងយុវជនជនជាតិដើមភាគតិចពូនង ជាក្រុមជនជាតិដើមមួយ ដែលរងផលប៉ះពាល់ពីការរឹបអូសដីធ្លីនិងការបង្ខំឱ្យប្តូរទីលំនៅជាយូរមកហើយ។[2]

ក្នុងរយៈពេលជាបន្តបន្ទាប់ គាត់បានសង្កេតឃើញការប្រែប្រួលយ៉ាងជ្រាលជ្រៅ។ ស្ត្រីដែលធ្លាប់តែស្ងៀមស្ងាត់ចំពោះការចរចា បានចាប់ផ្តើមនិយាយអំពីសិទ្ធិរបស់ពួកគេ ជាពិសេសក្នុងករណីរឹបអូសដីធ្លី ដែលក្លាយជាបញ្ហាទូទៅនៅតំបន់នោះ និងទូទាំងប្រទេសកម្ពុជា។ *«ដោយសារតែ*







រូបថត៖ សុធារី ក្នុងកំឡុងពេលអនុវត្តគម្រោងកសាងសន្តិភាព អន្តរជំនឿ ចម្រុះជាតិសាសន៍ ទាក់ទងនឹងការថែរក្សាធនធានធម្មជាតិ នៅចន្លោះឆ្នាំ ២០១៤ ដល់ ២០១៩។ ថតដោយបុគ្គលិកក្រុមការងារដើម្បីដោះស្រាយទំនាស់ ចែករំលែកដោយមានការអនុញ្ញាត។



រូបថត៖ សុធារី ថតជាមួយអ្នកចូលរួម ក្នុងកំឡុងយុទ្ធនាការទិវាជនជាតិដើម និងអន្តរជំនឿ ក្នុងខេត្តកំពង់ស្ពឺ ឆ្នាំ២០១៧ ចែករំលែកដោយមានការអនុញ្ញាត។



រូបថត៖ សុធារីនៅការិយាល័យអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ នៅកណ្តាលក្រុងភ្នំពេញ ឆ្នាំ២០២៥។ ថតដោយ ឃ្លាំង ម៉ូលីនីន អង្គការនារីដើម្បីសន្តិភាព។

*ការចូលរួមជាបន្តបន្ទាប់ ស្ត្រីឥឡូវនេះ មានកម្លាំងចិត្តក្នុងការបញ្ចេញសំឡេងរបស់ពួកគេក្នុងសហគមន៍អំពីបញ្ហាដែលទាក់ទងនឹងជម្លោះ និងសន្តិភាព»* គាត់បាននិយាយដោយមោទនភាព។ ដោយការបង្កើតកន្លែងសម្រាប់ឱ្យស្ត្រីទាំងនេះបាននិយាយនិងបានស្តាប់ គាត់បានគាំទ្រឱ្យអ្នកភូមិក្លាយជាអ្នកដោះស្រាយជម្លោះដោយខ្លួនឯង។ វិធីសាស្ត្រចូលរួមនេះមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាជាក់លាក់ (ដូចជាការរឹបអូសដីធ្លីដោយអយុត្តិធម៌) ហើយក៏បានជួយស្តារឡើងវិញនូវការមិនទុកចិត្តជាប្រវត្តិសាស្ត្ររវាងគ្រួសារជនជាតិដើម អាជ្ញាធរមូលដ្ឋាន និងប្រជាជនខ្មែរភាគច្រើន។

សុធារីបានពន្យល់ថា វិធីសាស្ត្រផ្សះផ្សារបស់គាត់មិនមែនគ្រាន់តែជាការរៀបចំកិច្ចប្រជុំទេ តែវាជាការបីបាច់សម្រាប់ការព្យាបាល និងការយល់ចិត្ត។ មិនថាជាការចរចាជម្លោះដីធ្លី ឬបញ្ហាដែលបង្កជម្លោះរវាងជនជាតិដើមនិងជនជាតិផ្សេងទៀត គាត់បានចាប់ផ្តើមដោយការបង្កើតកន្លែងសុវត្ថិភាពសម្រាប់ភាគីទាំងអស់ ដើម្បីចែករំលែកបញ្ហានិងទស្សនៈរបស់ខ្លួន។ គាត់ជួយឱ្យមនុស្សពីរភាគីផ្ទុយគ្នាប្រែចិត្តនិងស្តាប់រឿងរ៉ាវរបស់គ្នាទៅវិញទៅមក។ *«ខ្ញុំចង់នាំមនុស្សផ្សេងៗមកជួបគ្នា មិនថាពួកគេកាន់សាសនា ឬប្រពៃណីផ្សេងគ្នា ហើយជួយឱ្យពួកគេផ្សះផ្សាគ្នា»* សុធារីបាននិយាយ។

គាត់អះអាងថា ការបង្ហាញពីភាពសុភាពរាបសានិងការអនុគ្រោះចំពោះគ្នា គឺបានបង្កើតលក្ខខណ្ឌសម្រាប់ការយល់ដឹងរួម។ សហគមន៍ដែលធ្លាប់មើលគ្នាជាសត្រូវ ឬជា «អ្នកដទៃ» អាចស្វែងរកចំណុចរួមតាមរយៈការសន្ទនាដែលមានការសម្របសម្រួល។ ការផ្សះផ្សានៅមូលដ្ឋានជួយស្តារឡើងវិញនូវទំនុកចិត្ត កាត់បន្ថយការរើសអើង និងបង្កើតជាមូលដ្ឋានសម្រាប់ការដោះស្រាយបញ្ហារួមនៅអនាគត។ នៅពេលអនុវត្តតាមទស្សនៈអន្តរសាសនា គាត់បានពន្យល់ថា៖ *«ជាអ្នកអន្តរសាសនា ខ្ញុំមិនតំណាងឱ្យសាសនាណាមួយទេ។ ខ្ញុំតំណាងសាសនាទាំងអស់ ហើយព្យាយាមឱ្យមនុស្សបំបែកការយល់ឃើញរបស់គេ ជាលំដាប់ថ្នាក់ ទាំងក្នុងសាសនា និងរវាងសាសនាផ្សេងៗ»*។

ទោះជាយ៉ាងណា ក៏សុធារីទទួលស្គាល់ថា ការស្ថាបនាសន្តិភាពតាមរយៈអន្តរសាសនាមិនមែនជារឿងងាយស្រួលទេ ជាពិសេសសម្រាប់ស្ត្រី។ *«វាជាបញ្ហាប្រឈម ពីព្រោះនៅក្នុងសាសនាធំៗទាំងអស់ តួនាទីដឹកនាំភាគច្រើនត្រូវបានរក្សាសម្រាប់បុរស»* គាត់បានប្រាប់យើង *«ពុទ្ធសាសនា អ៊ីស្លាម និងគ្រីស្ទានទាំងអស់សុទ្ធតែមានគំនិតដាក់កម្រិតអំពីតួនាទីស្ត្រី»*។

ក្នុងរយៈពេលជាបន្តបន្ទាប់ សុធារីបានរកឃើញថា ការគោរពនិងការព្យាយាមអនុវត្តអាចបម្លែងផ្នត់គំនិតបាន។ គាត់បានពន្យល់ថា៖ *«នៅពេលពួកគេចូលរួមវគ្គបណ្តុះបណ្តាលជាមួយខ្ញុំ ពួកគេអាចឃើញជាឧទាហរណ៍ថា ខ្ញុំមានការគោរពចំពោះព្រះសង្ឃ។ បន្ទាប់មក ពួកគេចាប់ផ្តើមយល់អំពីវិធីសាស្ត្រអន្តរសាសនា ជាយន្តការសម្រាប់ការស្តាប់ ការយល់ដឹង និងការទទួលយកគ្នាទៅវិញទៅមក ព្រមទាំងការចៀសវាងការវាយតម្លៃ ឬការរើសអើងផ្អែកលើសាសនា»*។ តាមរយៈកិច្ចសន្ទនានិងការអនុវត្តដោយអត់ធ្មត់ ការងាររបស់គាត់បានបង្ហាញថា អន្តរសាសនាមិនមែនជាការកាត់បន្ថយសាសនាណាមួយទេ ប៉ុន្តែជាការបង្កើតកន្លែងសម្រាប់សាសនាទាំងអស់។ វិធីសាស្ត្រនេះ បានអនុញ្ញាតឱ្យគាត់បង្កើតសម្ព័ន្ធភាពជាមួយអ្នកដឹកនាំសាសនាដែលធ្លាប់តែមានការសង្ស័យ និងប្រជាជនទូទៅ ដើម្បីបើកទ្វារឱ្យស្ត្រីកសាងសន្តិភាពត្រូវបានទទួលស្គាល់ថា ជាអ្នកចូលរួមដោយស្របច្បាប់ក្នុងវិស័យដែលធ្លាប់តែគ្របដណ្តប់ដោយបុរស។

សុធារីក៏បាននិយាយដោយស្មោះត្រង់អំពីបញ្ហាប្រឈមធំៗ ដែលអ្នកកសាងសន្តិភាពប្រឈមមុខនៅកម្ពុជា ដែលអតុល្យភាពនៃអំណាច និងមរតកនៃភាពមិនទទួលខុសត្រូវ ជាឧបសគ្គសម្រាប់ការដោះស្រាយជម្លោះក្នុងមូលដ្ឋាន។ ជម្លោះជាច្រើន ដូចជាអំពីដីធ្លី ព្រៃ ទន្លេ ឬគម្រោងអភិវឌ្ឍន៍ ជាផ្នែកមួយនៃការប្រឆាំងគ្នារវាងសហគមន៍ក្រីក្រ និងក្រុមហ៊ុនធំៗ ឬអ្នកមានអំណាច។ គាត់បានបញ្ជាក់បន្ថែមថា ក្នុងករណីដូច្នេះ *«អ្នកដែលគ្មានអំណាចមិនអាចធ្វើអ្វីបានទេ ឬត្រូវចំណាយពេលយ៉ាងយូរ»* ដោយជម្លោះខ្លះអាចបន្តរយៈពេលជាច្រើនទសវត្សរ៍ ខណៈពេលសហគមន៍រងទុក្ខវេទនា។[2] អំពើពុករលួយនិងការអនុវត្តច្បាប់ទន់ខ្សោយតែងតែបណ្តោយឱ្យក្រុមអ្នកមានអំណាចធ្វើសកម្មភាពដោយនិទណ្ឌភាព ដែលកិច្ចប្រឹងប្រែងសន្តិភាពអាចត្រូវដួលរលំ។

ដោយដឹងថា បញ្ហាដែលមិនបានដោះស្រាយអាចបង្កជាជម្លោះនាពេលអនាគត សុធារីបន្តផ្តោតលើការបង្ការ។ គាត់ធ្វើការជាមួយបណ្តាញសង្គមស៊ីវិល ដើម្បីដោះស្រាយឫសគល់ដោយជំរុញគោលនយោបាយដីធ្លីយុត្តិធម៌ ការទទួលខុសត្រូវពីអាជ្ញាធរ និងកិច្ចសន្ទនារវាងប្រជាពលរដ្ឋនិងមន្ត្រី។ ជាញឹកញាប់ភាពរីកចម្រើនប្រព្រឹត្តទៅយ៉ាងយឺត និងគួរឱ្យខកចិត្ត

ប៉ុន្តែគាត់ជឿជាក់ថា វាជាវិធីតែមួយគត់ដើម្បីបំបែកវដ្តនៃជម្លោះ។ ដោយជោគជ័យតូចៗទីមួយៗ កិច្ចព្រមព្រៀងដែលបានចរចា ការដាក់ពាក្យស្នើសុំរបស់សហគមន៍ដែលជួយបញ្ចៀសការបណ្តេញចេញ បានក្លាយជាជំហានទីមួយៗឆ្ពោះទៅកាន់សន្តិភាព។ សុធារីបានពន្យល់ថា ដំណើរការដោះស្រាយបញ្ហា ដោយការចូលរួមមានសារៈសំខាន់ដូចជាលទ្ធផលដែរ ដោយសារតែវាជួយបង្កើនសមត្ថភាពរបស់សហគមន៍ ដើម្បីដោះស្រាយជម្លោះដោយសន្តិវិធីនៅពេលក្រោយទៀត។

## ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ (WPS)

ក្នុងនាមជាស្ត្រីអ្នកដឹកនាំម្នាក់ក្នុងវិស័យដែលភាគច្រើនគ្របដណ្តប់ដោយបុរស សុធារីបានបង្កើតវិធីសាស្ត្រផ្ទាល់ខ្លួននៃសសរ «ការចូលរួម» ក្នុងរបៀបវារៈ WPS។ គាត់មិនត្រឹមតែមានតួនាទីដឹកនាំផ្ទាល់នោះទេ ប៉ុន្តែបានជំរុញឱ្យស្ត្រីផ្សេងទៀតមានសំឡេងក្នុងដំណើរការសន្តិភាព និងការផ្សះផ្សាផងដែរ។ គាត់បានបញ្ជាក់ថា ស្ត្រីកម្ពុជាជាច្រើនបានជួយចរចាជម្លោះក្នុងគ្រួសារ និងជាមួយអ្នកជិតខាងដោយស្ងៀមស្ងាត់ តែ *«ត្រូវមានការទទួលស្គាល់ និងការគាំទ្រច្រើនជាងនេះ ចំពោះតួនាទីស្ត្រីក្នុងការកសាងសន្តិភាព»* ពីព្រោះពួកគេ *«ប្រឈមមុខនឹងបញ្ហាប្រឈម និងឧបសគ្គជាច្រើន»* ក្នុងការចូលរួមសាធារណៈ។

សុធារីបានខិតខំបំផុសសកម្មភាពមិនផ្លូវការទាំងនេះឱ្យក្លាយជាតួនាទីផ្លូវការ។ គាត់បានរៀបចំវេទិកាស្ត្រីដើម្បីពិភាក្សាបញ្ហាសហគមន៍ និងជំរុញឱ្យស្ត្រីចូលរួមក្នុងគណៈកម្មការចរចាជម្លោះនៅតាមភូមិ ដើម្បីធ្វើឱ្យការចូលរួមរបស់ពួកគេមើលឃើញក្នុងការសម្រេចចិត្តសាធារណៈ។ ក្នុងរយៈពេលជាច្រើនឆ្នាំ គាត់បានក្លាយជាមគ្គុទ្ទេសក៍សម្រាប់សកម្មជនស្ត្រីវ័យក្មេង និងស្ម័គ្រចិត្ត ដោយជួយពួកគេបង្កើតទំនុកចិត្ត ដើម្បីលើកសំឡេងក្នុងកិច្ចប្រជុំ ដែលភាគច្រើនដឹកនាំដោយបុរស។

ក្នុងការអនុវត្តជាក់ស្តែង ការប្តេជ្ញាចិត្តរបស់សុធារីចំពោះការចូលរួមរបស់ស្ត្រីបានឆ្លុះបញ្ចាំងជាមួយការងារសហគមន៍ និងអន្តរសាសនារបស់គាត់។ គាត់បានពន្យល់អំពីស្ថានភាពស្មុគស្មាញនៃអត្តសញ្ញាណ និងការរើសអើងនៅកម្ពុជា ដែលភេទ សាសនា និងជនជាតិផ្សេងៗបានប៉ះពាល់ដល់បទពិសោធរបស់ស្ត្រី។ ជាពិសេសសុធារីបានរំលឹកអំពីការរើសអើងបីជាន់ ដែលស្ត្រីជនជាតិភាគតិចប្រឈមមុខ ឧទាហរណ៍ស្ត្រីជនជាតិចាមមូស្លីមត្រូវគេមើលរំលង ដោយសារភេទ ជនជាតិ និងអត្តសញ្ញាណសាសនារបស់ពួកគេ។

នាងបានបញ្ជាក់ដោយមោទនភាពថា ស្ត្រីនិងយុវជនជាច្រើន ដែលគាត់ធ្លាប់ធ្វើការជាមួយក្នុងរយៈពេលជាច្រើនឆ្នាំបានក្លាយជាអ្នកលើកសំឡេងអំពីសិទ្ធិមនុស្ស និងបញ្ហាការការពារសង្គម ហើយអាជ្ញាធរមូលដ្ឋានក៏បានឆ្លើយតបច្រើនជាងមុនផងដែរ។ នៅក្នុងប្រទេសមួយ ដែលស្ត្រីជនជាតិដើមភាគច្រើនគ្មានអំណាចផ្លូវការ ជោគជ័យទាំងនេះបង្ហាញពីគោលនយោបាយ WPS ដែលកំពុងអនុវត្តនៅមូលដ្ឋាន។

ក្រៅពីកម្រិតសហគមន៍ សុធារីក៏បានចូលរួមជំរុញគោលនយោបាយ WPS នៅកម្ពុជាផងដែរ។ គាត់ជាសំឡេងសង្គមស៊ីវិលសំខាន់មួយក្នុងការពិភាក្សាថ្នាក់ជាតិអំពីការអភិវឌ្ឍផែនការសកម្មភាពជាតិ (NAP) សម្រាប់ WPS ដែលជាក្របខ័ណ្ឌការងារដំបូងរបស់ប្រទេសសម្រាប់បញ្ចូលស្ត្រីក្នុងការខិតខំសន្តិភាពនិងសន្តិសុខ។

នៅចុងឆ្នាំ២០២៤ គាត់បានថ្លែងសុន្ទរកថា ក្នុងវគ្គបណ្តុះបណ្តាលអំពី WPS ដែលគាត់បានលើកឡើងថា សន្តិភាពនៅកម្ពុជា អាស្រ័យលើការដោះស្រាយអសមភាពរចនាសម្ព័ន្ធ។ គាត់បានជំរុញថា៖ *«នៅពេលយើងនិយាយអំពីសន្តិភាព និងអំពើហិង្សា យើងត្រូវប្រឈមមុខនឹងបញ្ហារចនាសម្ព័ន្ធ ដែលបន្តបង្កគ្រោះថ្នាក់ក្នុងសង្គមរបស់យើង។ ការដោះស្រាយបញ្ហាទាំងនេះពីមូលដ្ឋាន គឺសំខាន់ណាស់ ហើយគោលនយោបាយ WPS ត្រូវបានយល់យ៉ាងទូលំទូលាយ និងអនុវត្តជាក់ស្តែង»*។[4]

គាត់ក៏បានលើកឡើងដែរថា បញ្ហាដូចជាហិង្សាផ្អែកលើយេនឌ័រ អំពើពុករលួយ និងការរើសអើងជនជាតិភាគតិចមានទំនាក់ទំនងគ្នា ហើយត្រូវការទស្សនៈ WPS ដែលមានសក្តានុពល ដើម្បីដោះស្រាយ។ ដូចដែលគាត់បានប្រាប់យើងថា៖ *«វាកំពុងប្រសើរឡើងបន្តិចៗសម្រាប់ជំនាន់ស្ត្រីវ័យក្មេង ប៉ុន្តែមានការងារជាច្រើនត្រូវធ្វើ។ មានការខិតខំជាច្រើនឆ្នាំសម្រាប់ការលើកស្ទួយស្ត្រីនិងយេនឌ័រ ប៉ុន្តែយើងត្រូវការមើលឃើញការប្រែប្រួលច្រើនជាងនេះ»*។ តាមរយៈការជំរុញផែនការសកម្មភាពជាតិប្រកបដោយបរិយាបន្ន សុធារីកំពុងជួយបម្លែងភាពជោគជ័យនៅមូលដ្ឋានឱ្យក្លាយជាការប្តេជ្ញាថ្នាក់ជាតិ ដើម្បីធានាថាគោលនយោបាយគាំទ្រការលើកទឹកចិត្តស្ត្រី និងសុវត្ថិភាពស្ត្រីនៅមូលដ្ឋាន។

ក្រោមការដឹកនាំរបស់សុធារី ACT ក៏ត្រូវបានទទួលស្គាល់ដែរថា បានអនុវត្តគោលនយោបាយ WPS ជាក់ស្តែង។ ក្នុងឆ្នាំ២០២៤ ACT ជាមួយអង្គការប្រចាំតំបន់អាស៊ីអាគ្នេយ៍ចំនួន៩ផ្សេងទៀតត្រូវបានផ្តល់ពានរង្វាន់ក្នុងការប្រកួតប្រជែងអំពីការអនុវត្តល្អបំផុតស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលរៀបចំដោយ UN Women និងអាស៊ាន។[5] ពានរង្វាន់នេះបានបង្ហាញពីគម្រោង «សារព័ត៌មានដើម្បីសន្តិភាព» ប្រកបដោយភាពច្នៃប្រឌិតរបស់ ACT ដែលបណ្តុះបណ្តាលអ្នកសារព័ត៌មាន និងអ្នករាយការណ៍សហគមន៍ ដើម្បីលើកស្ទួយសន្តិភាព និងបរិយាបន្នតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ គម្រោងនេះ ដែលសុធារីជាអ្នកជំរុញ ហើយជាញឹកញាប់បានទៅដល់សហគមន៍ដាច់ស្រយាលជាច្រើននៅកម្ពុជា ដែលបានទទួលព័ត៌មានតិចតួច។

ដោយផលិតកម្មវិធីវិទ្យុ វីដេអូ និងអត្ថបទជាភាសាមូលដ្ឋាន គម្រោងនេះបានបំបាត់គម្លាតនៃទំនាក់ទំនងនិងផ្សព្វផ្សាយការយល់ដឹងអំពីការដោះស្រាយជម្លោះដោយសន្តិវិធី។ សុធារីបានពន្យល់ថា៖ «យើងចង់ឱ្យប្រព័ន្ធផ្សព្វផ្សាយមានតួនាទីជាសកម្មជន ដើម្បីអប់រំប្រជាជន និងផ្តល់ព័ត៌មានអំពីបញ្ហាសន្តិភាព»។ លទ្ធផលជាក់ស្តែង នៅខេត្តដាច់ស្រយាល ស្ត្រីដែលមិនធ្លាប់ចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយបានចាប់ផ្តើមស្តាប់រឿងរ៉ាវពីស្ត្រីផ្សេងទៀតដែលបានចរចាជម្លោះ ឬការពារសិទ្ធិដីធ្លីរបស់ពួកគេ ហើយបានទទួលការបំផុសចិត្តក្នុងការធ្វើដូចគ្នា។

ស្ត្រីនៅតំបន់ដាច់ស្រយាលទាំងនេះ ឥឡូវមានទំនុកចិត្តក្នុងការពិភាក្សាបញ្ហាជម្លោះ និងសន្តិភាព[6] ដែលជាលទ្ធផលសំខាន់មួយនៃគោលនយោបាយ WPS ដើម្បីអភិវឌ្ឍសមត្ថភាពស្ត្រីនៅមូលដ្ឋានក្នុងការចូលរួមកសាងសន្តិភាព និងបង្កើនភាពធន់នៃសហគមន៍។

## ឆ្ពោះទៅរកចក្ខុវិស័យសន្តិភាព និងភាពរួបរួមសង្គម

នៅគ្រប់ផ្នែកនៃការងាររបស់គាត់ គោលបំណងរបស់សុធារី គឺបង្កើនភាពរួបរួមសង្គមក្នុងសង្គមមួយ ដែលនៅតែមានស្លាកស្នាមសល់ពីសង្គ្រាម និងការបែងចែក។ គាត់យល់ថា សន្តិភាពមិនមែនជាការអវត្តមាននៃអំពើហិង្សាទេ។ ដូចដែលគាត់បាននិយាយថា៖ *«សន្តិភាព គឺជាអ្វីគ្រប់យ៉ាង... សេរីភាព យុត្តិធម៌សង្គម សុខភាពផ្លូវចិត្ត សុខុមាលភាព... វាជាគោលគំនិតសរុបបញ្ចូលគ្នា»* ដែលត្រូវការភាពបើកចំហ និងការទទួលខុសត្រូវពីអ្នកដឹកនាំផងដែរ។

ក្នុងកិច្ចសន្ទនានីមួយៗដែលគាត់សម្របសម្រួល និងគម្រោងនីមួយដែលគាត់ដឹកនាំ សុធារីខិតខំដើម្បីភ្ជាប់ភាពខុសគ្នា មិនថាជាសាសនា ជនជាតិ ភេទ ឬជំនាន់នោះទេ។ គាត់បាននាំអ្នកដែលធ្លាប់ជាសត្រូវមកជួបគ្នាដើម្បីស្វែងរកចំណុចរួម រាប់ចាប់ពីអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងអតីតកងកម្លាំងខ្មែរក្រហមដែលស្វែងរកការផ្សះផ្សា រហូតដល់អ្នកជិតខាងពុទ្ធសាសនា មូស្លីម និងគ្រីស្ទាន ដែលរួមគ្នាដោះស្រាយបញ្ហាសហគមន៍។ ដោយផ្សារភ្ជាប់មនុស្សជាមួយតម្លៃរួមនៃការអនុគ្រោះនិងការគោរព សកម្មភាពរបស់គាត់បានកាត់បន្ថយហានិភ័យនៃជម្លោះនាពេលអនាគត និងបង្កើតមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន។

សុធារីបានបញ្ជាក់ជាញឹកញាប់ថា ការស្ថាបនាសន្តិភាពនៅកម្ពុជាមានន័យថា ត្រូវឆ្លងកាត់ទាំងមរតកនៃអំពើហិង្សាកាលពីអតីតកាល និងការបែកបាក់សង្គមបច្ចុប្បន្ន រវាងសហគមន៍ទីក្រុងនិងជនបទ ប្រជាជនភាគច្រើននិងភាគតិច អ្នកមាននិងអ្នកក្រីក្រ។ល។ ទំនាក់ទំនងនីមួយៗដែលត្រូវជួសជុល និងក្រុមនីមួយៗដែលត្រូវនាំមកជួបគ្នា គឺជាជំហានមួយឆ្ពោះទៅរកការព្យាបាលសង្គមទាំងមូល។

ទោះបីជាគាត់បានកើនឡើងការទទួលស្គាល់ក៏ដោយ សុធារីនៅតែសុភាពរាបសា។ មិត្តរួមការងារពិពណ៌នាគាត់ថា ជាអ្នកដឹកនាំដែលមានចរិតសុភាពរាបសា និងនៅជាមួយប្រជាជនដែលគាត់ធ្វើការជាមួយ ដោយបានទទួលការគោរពយ៉ាងទូលំទូលាយ។ គាត់មានមោទនភាពក្នុងការរួមស្ថិតនៅជាមួយសហគមន៍ដែលគាត់បម្រើ ដើម្បីស្វែងយល់ពីការលំបាករបស់ពួកគេ និងជួយពួកគេស្វែងរកដំណោះស្រាយ។ នៅពេលរំលឹកពីឆ្នាំជាច្រើននៃការចូលរួម គាត់បាននិយាយថា៖ *«វាជាព្រះគុណសម្រាប់ខ្ញុំក្នុងការធ្វើការងារនៅកម្រិតសហគមន៍។ ខ្ញុំគិតថាយើងអាចនាំមនុស្សមកជួបគ្នាដើម្បីយល់គ្នាទៅវិញទៅមកបាន»*។ សម្រាប់រូបគាត់ ដំណើរការបង្កើតការយល់ដឹងពីគ្នា គឺសំខាន់ដូចជាកិច្ចព្រមព្រៀងផ្លូវការដែរ។

គាត់បន្តថា៖ *«យើងអាចជួយមនុស្សឱ្យគិតអំពីដំណើរការសន្តិភាពនៅទសវត្សរ៍១៩៩០ ដើម្បីនាំមេរៀនទាំងនោះចូលក្នុងជីវិតសព្វថ្ងៃរបស់ពួកគេ ដូច្នេះពួកគេអាចស្វែងរកដំណោះស្រាយផ្ទាល់ខ្លួនចំពោះជម្លោះ និងភាពតានតឹង»*។ តាមរបៀបនេះ គាត់បានភ្ជាប់ប្រវត្តិសាស្ត្រនៃការផ្សះផ្សាជាតិរបស់កម្ពុជាទៅនឹងបញ្ហាជម្លោះមូលដ្ឋានប្រចាំថ្ងៃ ដើម្បីបង្ហាញថា មេរៀនពីអតីតកាលអាចជំរុញឱ្យសហគមន៍បង្កើតផ្លូវសន្តិភាពផ្ទាល់ខ្លួន។

សម្រាប់សុធារី ទស្សនៈនេះមានសារៈសំខាន់ជាពិសេសនៅឆ្នាំ២០២៥ ខណៈដែលភាពតានតឹងនៅព្រំដែនកម្ពុជា–ថៃបានកើនឡើងម្តងទៀត។ គាត់បានជំរុញថា សមត្ថភាពរបស់សហគមន៍ក្នុងការយកបទពិសោធពីការកសាងសន្តិភាពកាលពីមុន មកអនុវត្តក្នុងការដោះស្រាយជម្លោះសព្វថ្ងៃ គឺសំខាន់ណាស់ ដើម្បីរំលឹកថា ការផ្សះផ្សាមិនមែនជាសមិទ្ធផលតែមួយដងទេ ប៉ុន្តែជាការអនុវត្តជាបន្តបន្ទាប់។

សុធារីក៏បានលើកឡើងផងដែរថា សន្តិភាពពិតប្រាកដត្រូវការការដោះស្រាយបញ្ហាជាច្រើនដែលមានទំនាក់ទំនងគ្នា ចាប់តាំងពីអំពើអយុត្តិធម៌ក្នុងប្រវត្តិសាស្ត្រ ភាពក្រីក្រ ទៅដល់វិបត្តិសុខភាពសាធារណៈ និងបញ្ហាអភិបាលកិច្ច ដែលប៉ះពាល់ដល់អារម្មណ៍សុវត្ថិភាពរបស់ប្រជាជន។ សមត្ថភាពរបស់គាត់ក្នុងការភ្ជាប់បញ្ហាធំៗទាំងនេះ ជាមួយសកម្មភាពនៅមូលដ្ឋាន បានធ្វើឱ្យគាត់ក្លាយជាស្ពានចម្លងដ៏ពិសេសរវាងគោលនយោបាយនិងសហគមន៍ សាសនានិងការអភិវឌ្ឍអតីតកាលនិងអនាគត។

សម្លឹងទៅអនាគត សុធារីនៅតែមានការយល់ឃើញដោយប្រុងប្រយ័ត្ន ប៉ុន្តែជឿជាក់ថា ភាពរីកចម្រើនអាចកើតមានបាន ប្រសិនបើមនុស្សគ្រប់គ្នាចូលរួមជាដៃគូ។ ក្នុងចក្ខុវិស័យរបស់គាត់ ប្រជាជនកម្ពុជាម្នាក់ៗ មិនថាកាន់សាសនាអ្វី ភេទអ្វី ឬមានប្រវត្តិផ្ទាល់ខ្លួនបែបណាទេ សុទ្ធតែមានតួនាទីក្នុងការចូលរួម៖ *«ការកសាងសន្តិភាពគឺជាផ្លូវដ៏វែងឆ្ងាយ ដែលយើងត្រូវដើរជាមួយគ្នាដោយភាពអត់ធ្មត់ ជាមួយភាពសុភាពរាបសា និងការអភ័យទោស ដើម្បីបម្លែងសហគមន៍របស់យើង»*។[6]









# ឯកសារយោង


1. United Religions Initiative (2018), **‘Celebrating World Interfaith Harmony in the Cambodian Forest,’** online: <https://www.uri.org/uri-story/20180228-celebrating-world-interfaith-harmony-cambodian-forest>.
2. UN Women (2023), *‘WPS-ASEAN Photo Exhibition: Srey Sotheavy,’* online: <https://act-kh.org/wp-content/uploads/2023/01/Sotheavy@UNwomenDec22.pdf>.
3. Freedom Asia (2020), *‘Interview with Ms. Srey Sotheavy, Executive Director at the Alliance for Conflict Transformation*, online: <https://freedomasia.org/?p=354&lang=en>.
4. UN Women (2024), *‘Making Peace Work for Everyone: Advancing Women, Peace, and Security in Cambodia,’* online: <https://cambodia.un.org/en/286457-making-peace-work-everyone-advancing-women-peace-and-security-cambodia>.
5. UN Women (2025) *‘PEACE Award: Civil Society Organizations Competition on Good Practices in WPS in Southeast Asia,’* online: <https://wps.asean.org/stories/announcement-peace-award/>.
6. Ibid.
7. Alliance for Conflict Transformation (n.d), *ACT Staff*, online: <https://act-kh.org/act-staffs/>.


